**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
**អគ្គនាយកដ្ឋានកសិកម្ម**

លេខ ១៧៥៦ អ.ន.ក

ថ្ងៃព្រហស្បតិ៍ ៨រោច ខែអាសាឍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៩

**សូមគោរពជូន**
**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីសកម្មភាពអនុវត្តការងារប្រចាំឆមាសទី១ ឆ្នាំ២០១៩ របស់អគ្គនាយកដ្ឋានកសិកម្ម។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទសូមអនុញ្ញាតរាយការណ៍ជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបនូវលទ្ធផលអនុវត្តសកម្មភាពការងាររបស់អគ្គនាយកដ្ឋានកសិកម្មប្រចាំឆមាសទី១ ឆ្នាំ២០១៩ មានដូចខាងក្រោម៖

I. **លទ្ធផលបង្កបង្កើនផលកសិកម្មរដូវវស្សាឆ្នាំ២០១៩** (គិតត្រឹមថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៩)

**១. ដំណាំស្រូវ** : ផ្ទៃដីស្ទូងព្រោះសរុបអនុវត្តបានចំនួន ១.២៨៣.៩៦២ ហ.ត ស្មើនឹង៤៩,៦៥% នៃផែនការចំនួន ២.៥៨៦.១៥២ ហ.ត យឺតជាងឆ្នាំមុនចំនួន ២១០.៧៣៣ ហ.ត

- ការងារភ្ជួររាស់ដី : ផ្ទៃដីភ្ជួររាស់សរុបអនុវត្តបាន ១.៥៤៨.៧៣៤ ហ.ត យឺតជាងឆ្នាំមុនចំនួន ២៣៧.២២៥ ហ.ត ក្នុងនោះផ្ទៃដីភ្ជួររាស់ដោយគ្រឿងយន្តចំនួន ១.៥៣៤.៤៦៣ហ.ត ស្មើនឹង៩៩,០៧%
- ផ្ទៃដីសាបសរុប : ៦.៥៤៩ ហ.ត យឺតជាងឆ្នាំមុនចំនួន ១២.៨៩៩ ហ.ត







*ក្រាហ្វិក៖ ស្ថិតិផ្ទៃដីភ្ជួររាស់ និងដាំដុះស្រូវរដូវវស្សាពីឆ្នាំ២០១៥-២០១៩ គិតត្រឹមឆមាសទី១ នៃឆ្នាំ*

តាមក្រាហ្វិកខាងលើបង្ហាញថា ក្នុងរយៈពេល៥ឆ្នាំដូចគ្នាគិតត្រឹមឆមាសទី១ ផ្ទៃដីភ្ជួររាស់ និងផ្ទៃដីដាំដុះរដូវវស្សាឆ្នាំ២០១៩ អនុវត្តយឺតជាងបណ្តាឆ្នាំមុនៗ។

**២. ដំណាំរួមផ្សំ** : អនុវត្តបានចំនួន ៣១.១១៩ ហ.ត យឺតជាងឆ្នាំមុនចំនួន ៣.៧២៤ ហ.ត។

**៣. ដំណាំឧស្សាហកម្ម** : អនុវត្តបានចំនួន ៥៦៨.៩១៥ ហ.ត យឺតជាងឆ្នាំមុនចំនួន ១២៥.៦៤៤ ហ.ត។


អាសយដ្ឋានលេខ: ៥៤បេ/៤៩អេហ្វ ផ្លូវលេខ ៣៩៥-៦៥៦ សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទលេខ:(០២៣) ៨៨៣ ៤២៧ ទូរសារលេខ:(០២៣) ៨៨៣ ៤២៧
Address # 54B/49F, Street 395-656, Sangkat Toeuk Laak 3, Khan Tuol Kok, Phnom Penh. Cambodia, Phone : (023) 883 427, Fax : (023) 883 427